រាជបណ្ឌិត្យសភាកម្ពុជា

# អគារឥន្ទ្រទេវី
# នៃរាជបណ្ឌិត្យសភាកម្ពុជា




**រៀបចំនិងចងក្រងដោយ៖**

ឯកឧត្តមបណ្ឌិត យង់ ពៅ លោកបណ្ឌិត ផុន កសិកា ឯកឧត្តមបណ្ឌិត ខែក វីរៈ លោកស្រី ម៉ិល វាសនា
កញ្ញា តាកេត ស័កដា លោក ជ ច័ន្ទតារា លោក ហឿង សុធារស់ និង លោក លឹម សុក្រាត



ឆ្នាំ២០១៩

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**I. សាវតារនៃអគារនៅរាជបណ្ណិត្យសភាកម្ពុជា**

១- សាវតារនៃទីតាំងនិងអគារនៅរាជបណ្ឌិត្យសភាកម្ពុជា ........ ២

២- ស្ថានភាពអគារដើម ........ ៣

**II. ការដាក់ឈ្មោះអគារ « ឥន្ទ្រទេវី » និងបដិមាព្រះនាងឥន្ទ្រទេវី**

១- ការដាក់ឈ្មោះអគារ «ឥន្ទ្រទេវី» ........ ៩

២- ការកំណត់អត្តសញ្ញាណព្រះនាងឥន្ទ្រទេវី ........ ១០

**III. ការរៀបចំប្លង់ស្ថាបត្យកម្ម និងដំណើរការសាងសង់**

១- ការរៀបចំប្លង់ស្ថាបត្យកម្ម ........ ២១

២- ដំណើរការសាងសង់ ........ ៣០

ការកែប្រែប្លង់អគារ ........ ៣១

ដំណាក់កាលបញ្ចប់ ........ ៣៦

៣- ការប្រើប្រាស់អគារ

- ជាន់ផ្ទាល់ដី ........ ៤១
- ជាន់ទី១ ........ ៤២
- ជាន់ទី២ ........ ៤៣
- ជាន់ទី៣ ........ ៤៤

ឯកសារពិគ្រោះ ........ ៤៨

អ្នកផ្តល់បទសម្ភាស ........ ៤៨

# សេចក្តីផ្តើម

រាជបណ្ឌិត្យសភាកម្ពុជាត្រូវបានបង្កើតឡើងនិងមានដំណើរការចាប់ពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជា *ធនាគារខួរក្បាល* របស់ជាតិ ដោយស្ថាប័ននេះបានប្រមូលផ្តុំនូវបញ្ញវន្តជាច្រើនរបស់ជាតិដើម្បីបម្រើការងារក្នុងវិស័យស្រាវជ្រាវវិទ្យាសាស្ត្រ។ ជាមួយគ្នានេះដែរ រាជបណ្ឌិត្យសភាកម្ពុជាក៏បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាលធនធានមនុស្សរបស់ជាតិ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ រាជបណ្ឌិត្យសភាកម្ពុជាបានឆ្លងកាត់អ្នកដឹកនាំចំនួនបីរូបគឺ ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា និងឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច នាពេលបច្ចុប្បន្ននេះ។ អ្នកដឹកនាំទាំងបីរូបបានសាងនូវសមិទ្ធផលបន្តវេនគ្នាជាបន្តបន្ទាប់ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គុណភាពការងារ និងកិត្យានុភាពស្ថាប័ន។ បច្ចុប្បន្ននេះ រាជបណ្ឌិត្យសភាកម្ពុជាក្នុងជំនាន់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច គឺកាន់តែទទួលបាននូវទំនុកចិត្តពីរាជរដ្ឋាភិបាល ហើយត្រូវរាជរដ្ឋាភិបាលសម្រេចផ្តល់នូវសំណង់អគារធំៗចំនួនពីរ សម្រាប់បំពេញតម្រូវការរបស់ស្ថាប័នគឺ អគារឥន្ទ្រទេវី និងអគារខេមរវិទូ។

អគារឥន្ទ្រទេវីជាអគារដែលបង្កើតឡើងសម្រាប់បម្រើការងារបណ្តុះបណ្តាល ជាពិសេសភាសាចិនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត។ អគារនេះបានទទួលការឧបត្ថម្ភពី**សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន** តាមរយៈអ្នកឧកញ៉ា ពុង ឃាវសែ។ ដោយផ្សារភ្ជាប់នឹងនាមអគារនេះ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំសិក្សាកំណត់អត្តសញ្ញាណព្រះនាងឥន្ទ្រទេវី ដើម្បីសិតបដិមាព្រះនាងជាទោល តម្កល់ក្បែរអគារជាទីគោរពសក្ការៈ។ រាជបណ្ឌិត្យសភាកម្ពុជាបានបង្កើតក្រុមសិក្សាស្រាវជ្រាវ និងបានរៀបចំសិក្ខាសាលាមួយ ដែលមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិមកពីក្រសួងស្ថាប័នផ្សេងៗ ហើយបានឈានដល់ការឯកភាពគ្នាកំណត់សិតបដិមាព្រះនាងឥន្ទ្រទេវីជាទោល ដោយយកតាមរូបចម្លាក់នៅជាប់ជញ្ជាំងប្រាសាទព្រះខ័ន។ ការសិតបដិមាព្រះនាងឥន្ទ្រទេវីអំពីស្ពាន់និងបុស្បុកសម្រាប់តម្កល់រក្សាបដិមាព្រះនាង គឺទទួលបានការឧបត្ថម្ភគាំទ្រពីលោកជំទាវឧកញ៉ា សៀង ចាន់ហេង ។

ឯកសារជាមរតកប្រវត្តិសាស្ត្រនៃសមិទ្ធផលដ៏វិសេសវិសាលនេះ ត្រូវបានរៀបចំឡើងតាមគំនិតផ្តួចផ្តើមរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងឯកឧត្តមបណ្ឌិត យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា។ ឯកសារនេះមានតម្លៃទាំងខាងវប្បធម៌ ប្រវត្តិសាស្ត្រ សង្គម និងវិទ្យាសាស្ត្រ ដោយបានរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗដូចជា សារតារនៃអគារនៅរាជបណ្ឌិត្យសភាកម្ពុជា ការដាក់ឈ្មោះអគារ « ឥន្ទ្រទេវី » ការកំណត់អត្តសញ្ញាណបដិមាព្រះនាងឥន្ទ្រទេវី និងការសិតបដិមាព្រះនាងជាទោល ការរៀបចំប្លង់ស្ថាបត្យកម្ម និងដំណើរការសាងសង់អគារឥន្ទ្រទេវីជាដើម។

# I. សាវតារនៃអគារនៅរាជបណ្ឌិត្យសភាកម្ពុជា

## ១- សាវតារនៃទីតាំងនិងអគារនៅរាជបណ្ឌិត្យសភាកម្ពុជា

អគារទាំងឡាយនៅក្នុងបរិវេណរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ និងរាជបណ្ឌិត្យសភាកម្ពុជា បានចាប់ផ្តើមកសាងឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៨៩ ហើយបានបញ្ចប់រួចរាល់ជាស្ថាពរនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩១ ដែលមានស្ថាបត្យករឬអ្នកគូរប្លង់អគារជាជនជាតិខ្មែរ (មានរចនាបថខ្មែរដូចជា ដំបូលខាងមុខ មានស្ពានហាល មានទឹកអមសងខាងស្ពានដូចអង្គរជាដើម) និងមានវិស្វករសាងសង់ជាជនជាតិវៀតណាម។ អគារទាំងនេះគឺជាអំណោយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមផ្តល់ជូនមកកម្ពុជានៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងគោលបំណងបង្កើតជាសាលានយោបាយមជ្ឈិម ដើម្បីបណ្តុះបណ្តាលកម្មាភិបាលជាន់ខ្ពស់ ឬ ហៅថា កម្មាភិបាលថ្នាក់ស្រុក ថ្នាក់ខេត្ត ជំនាន់នោះ លើផ្នែកទ្រឹស្តីនយោបាយ ការគ្រប់គ្រងរដ្ឋបាល និង ការគ្រប់គ្រងសេដ្ឋកិច្ច ជាដើម[១]។ តាមពិត នៅពេលនោះ សាលានយោបាយមជ្ឈិម គឺមានទីតាំងនៅវិទ្យាស្ថានភាសាបរទេស (IFL) បច្ចុប្បន្ន និង មានដំណើរការបណ្តុះបណ្តាលកម្មាភិបាលរួចហើយ តែដោយនៅទីនោះមានលក្ខណៈតូចចង្អៀត មិនមានទីកន្លែងស្នាក់នៅគ្រប់គ្រាន់ ហើយបណ្តុះបណ្តាលសិក្ខាកាមបានចំនួនតិច មិនអាចបំពេញទៅតាមតម្រូវការជាក់ស្តែងរបស់ប្រទេសជាតិនៅដំណាក់កាលនោះបាន ទើបថ្នាក់ដឹកនាំនៃប្រទេសកម្ពុជាសម័យកាលនោះ ស្នើសុំឱ្យប្រទេសវៀតណាមជួយកសាងសាលានយោបាយមជ្ឈិមថ្មីដែលសមស្របទៅតាមស្ថានភាពនិងតម្រូវការជាក់ស្តែង។ ដូច្នេះ សាលានយោបាយមជ្ឈិមនឹងផ្លាស់ប្តូរទីតាំងពីវិទ្យាស្ថានភាសាបរទេស (IFL) មកទីតាំងសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ និងរាជបណ្ឌិត្យសភាកម្ពុជា បច្ចុប្បន្ន បន្ទាប់ពីបានសាងសង់រួចរាល់ជាស្ថាពរ។

ដោយស្ថានភាពនយោបាយប្រទេសជាតិមានការផ្លាស់ប្តូរ ភាគីជម្លោះទាំងឡាយនៅកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយនៅទីក្រុងប៉ារីស សាលានេះពុំបានដំណើរការទៅតាមគោលបំណងឡើយ។ បន្ទាប់ពីការសាងសង់បានបញ្ចប់រួចរាល់ជាស្ថាពរ ភាគីវៀតណាមបានប្រគល់មកឱ្យកម្ពុជា ហើយ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** បានប្រគល់សាលានោះមកឱ្យក្រសួងអប់រំ យុវជន និង កីឡា។ ក្រសួងបានប្រគល់សាលានោះបន្តឱ្យមកសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីបំពេញទៅតាមតម្រូវការរបស់សាកលវិទ្យាល័យ ហើយវាបានក្លាយជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ ដែលសិក្សាលើមុខវិជ្ជា ទស្សនវិជ្ជា និង ប្រវត្តិវិទ្យា ហើយក្រោយមក នៅឆ្នាំ១៩៩៤ មានបង្កើតមុខវិជ្ជាសង្គមវិជ្ជា ក្រោមជំនួយគាំទ្រពីអង្គការមនុស្សលោកថ្មី (New Humanity) របស់ប្រទេសអ៊ីតាលី។

តាមគម្រោងប្លង់ដើមរបស់សាលានយោបាយមជ្ឈិម អគារទាំងឡាយនៅផ្នែកខាងមុខ (អគារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២បច្ចុប្បន្ន) គឺសម្រាប់បម្រើដល់ការសិក្សារៀនសូត្រ និងការ

[១] អ៊ុំ ប៉ុម ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា។

ប្រជុំនានារបស់កម្មាភិបាលជាសិក្ខាកាម ហើយផ្នែកខាងក្រោយ (អគារនៃរាជបណ្ឌិត្យសភកម្ពុជានាពេលបច្ចុប្បន្ន) គឺសម្រាប់បម្រើជាកន្លែងស្នាក់នៅនិងទទួលទានអាហារ។

២- ស្ថានភាពអគារដើម

អគារទាំងឡាយនៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា រួមមានអគារ A B C D E F និងG។ ដូចបានបញ្ជាក់ជូនខាងលើ ដំបូងឡើយ អគារទាំងឡាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ពុំមែនកសាងឡើងដើម្បីជាកន្លែងបម្រើកិច្ចការរដ្ឋបាល ឬកន្លែងធ្វើការងារស្រាវជ្រាវឡើយ តែសម្រាប់បម្រើកិច្ចការមួយចំនួនផ្សេងពីនេះ ដូចជា អគារ A[២] សម្រាប់បម្រើជាអាហារដ្ឋាន អគារ C និង E ជាទីកន្លែងស្នាក់នៅរបស់សិក្ខាកាម អគារ D ជាទីកន្លែងសម្រាប់ទទួលភ្ញៀវមកជួបសិក្ខាកាម អគារ B ជាអតីតទីតាំងស៊ីទែនទឹក អគារ F ជាអតីតរោងដាក់ឡាន និងម៉ូទ័របូមទឹកធំៗសម្រាប់ផ្គត់ផ្គង់ទឹកនៅក្នុងមណ្ឌលទាំងមូល ចំណែកឯអគារ G ជាកន្លែងស្នាក់នៅរបស់ក្រុមសន្តិសុខ។

បន្ទាប់ពីអគារទាំងនេះ ត្រូវបានប្រគល់មកជាទីកន្លែងសម្រាប់បម្រើការងាររបស់រាជបណ្ឌិត្យសភាកម្ពុជា ស្ថានភាពអគារទាំងនេះ ទាមទារឱ្យមានការជួសជុល កែលម្អ និងកសាងអគារថ្មីបន្ថែមទៀតដើម្បីឱ្យសមស្របទៅតាមគោលបំណងប្រើប្រាស់របស់ស្ថាប័ន។ ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង អតីតប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជាជំនាន់ទី១ដទៃទៀត បានខិតខំជួសជុល កែលម្អ និងកែប្រែអគារទាំងនោះទៅតាមលទ្ធភាព សម្រាប់ជាកន្លែងបម្រើការងាររដ្ឋបាល ជាថ្នាក់រៀនសម្រាប់បណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត និងជាកន្លែងបម្រើការងារនៃមន្ត្រីស្រាវជ្រាវរបស់វិទ្យាស្ថាន និងមជ្ឈមណ្ឌលនីមួយៗ។ ការជួសជុលកែលម្អនេះជាការត្រួសត្រាយជាមូលដ្ឋានមួយលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់អ្នកបន្តវេន។

---

[២] នៅអគារ A ជាន់ផ្ទាល់ដីគឺសម្រាប់ដាំស្ល ហើយជាន់ខាងលើគឺសម្រាប់ទទួលទានអាហារ។




ទិដ្ឋភាពអគារ A នៅដំណាក់កាលដំបូង




ទិដ្ឋភាពខាងក្នុងនៃអគារ A

បន្តមកដល់លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងថ្នាក់ដឹកនាំជំទែទៀតជាជំនាន់ទី២ តាមរយៈជំនួយឧបត្ថម្ភគាំទ្រទាំងឡាយបានបន្តកែប្រែមុខមាត់រាជបណ្ឌិត្យសភាកម្ពុជាបន្ថែមទៀតដោយឱ្យមានទីកន្លែងសមរម្យជាងមុនសម្រាប់បម្រើការងារវិស័យស្រាវជ្រាវវិទ្យាសាស្ត្រ។ អគារA ដែលសាងសង់ឡើងសម្រាប់ជាអាហារដ្ឋាន (នៅជាន់ផ្ទាល់ដីសម្រាប់ដាំស្ល ហើយជាន់ខាងលើសម្រាប់ទទួលទានអាហារ) ត្រូវជួសជុលកែលម្អបន្ថែមទៀតសម្រាប់បម្រើការជាអគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា ជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលភាសាអង់គ្លេសកម្ពុជា-ឥណ្ឌា ជាមជ្ឈមណ្ឌលព័ត៌មានវិទ្យា និងជាសាលសន្និសីទរាជបណ្ឌិត្យសភាកម្ពុជា។ សាលប្រជុំដែលសាងសង់ឡើងសម្រាប់ជាទីកន្លែងទទួលទានអាហារដ្ឋាន មានលក្ខណៈតូចចង្អៀត ពុំមានបំពាក់ឧបករណ៍គ្រប់គ្រាន់សម្រាប់បម្រើការរៀបចំវេទិកាវិទ្យាសាស្ត្រនិងកិច្ចប្រជុំធំៗ ត្រូវបានជួសជុលកែលម្អជាសាលសន្និសីទរាជបណ្ឌិត្យសភាកម្ពុជា ដែលមានលក្ខណៈកាន់តែធំទូលាយនិងមានសោភ័ណភាពក្លាយជាទីកន្លែងសម្រាប់រៀបចំវេទិកាវិទ្យាសាស្ត្រនានា ជាសិក្ខាសាលា ជាសន្និសីទ និងកិច្ចប្រជុំតូច ធំ ទាំងកម្រិតជាតិ និងអន្តរជាតិ ធ្វើឱ្យរាជបណ្ឌិត្យសភាកម្ពុជាចំណេញថវិកាពីសាលសន្និសីទនេះ ដោយពុំបានចំណាយលើការជួលទីតាំងសម្រាប់រៀបចំវេទិកាទាំងនេះ[៣]។ អគារបណ្ឌិតសភាចារ្យ (អគារ F) ដែលមានកម្ពស់ពីរជាន់ មានបំពាក់គ្រឿងបរិក្ខារគ្រប់គ្រាន់និងប្រកបដោយផាសុកភាព បានសាងសង់ឡើងសម្រាប់ជាទីកន្លែងបម្រើការងារស្រាវជ្រាវរបស់បណ្ឌិតសភាចារ្យគ្រប់រូប[៤]។ ក្រៅពីនេះ នៅមានជំនួយឧបត្ថម្ភពីសប្បុរសជនជាច្រើនផ្សេងទៀតដូចជា ការលាបថ្នាំពណ៌អគារទាំងឡាយរបស់រាជបណ្ឌិត្យសភាកម្ពុជាជាថ្មី[៥] ការសាងសង់ព័ត៌មានដ្ឋាន (អគារ B)[៦] និងការជួសជុលកែលម្អអគារសម្រាប់ទីប្រឹក្សា និងជំនួយការរាជបណ្ឌិត្យសភាកម្ពុជា(អគារ G)[៧]ជាដើម។

[៣] ជំនួយឧបត្ថម្ភគាំទ្រពីសម្ដេចវិបុលបញ្ញាបណ្ឌិតសភាចារ្យ សុខ អាន តាមរយៈឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ៅ សុផាន់ មេបញ្ជាការកងពលតូចលេខ៧០។

[៤] ជំនួយឧបត្ថម្ភពីឯកឧត្តមបណ្ឌិត ច័ន្ទ សារុន និង លោកជំទាវ សុខ កែវ។

[៥] ជំនួយឧបត្ថម្ភពីឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ៅ សុផាន់ មេបញ្ជាការកងពលតូចលេខ៧០។

[៦] ជំនួយឧបត្ថម្ភពីលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា , លោកជំទាវឧកញ៉ា ញ៉ឹក ប៊ុនថា និងឯកឧត្តម ស៊ឹម ហ៊ាង និង លោកជំទាវ។

[៧] ជំនួយឧបត្ថម្ភពី អ្នកឧកញ៉ា និងលោកជំទាវ សុខា ផល្លី។



ទិដ្ឋភាពអគារ A ក្រោយការជួសជុលកែលម្អក្នុងអាណត្តិប្រធានទី២



ទិដ្ឋភាពខាងក្នុងនៃអគារ A ក្រោយការជួសជុលកែលម្អ

ក្រោយមក ស្ថានភាពនៃអគារ A មានការលេច និងជ្រាបទឹកដោយអន្លើ មាននៅផ្នែកខាងក្រៅ និងផ្នែកខាងក្នុងនៃសាលសន្និសីទរាជបណ្ឌិត្យសភាកម្ពុជា ដែលនាំឱ្យប៉ះពាល់ដល់គុណភាព និងសោភ័ណភាពរបស់អគារ។

ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច រាជបណ្ឌិត្យសភាកម្ពុជាទទួលអគារពីរជាអំណោយដ៏ថ្លៃថ្លាបំផុតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយអគារទី១ មានឈ្មោះថា *អគារខេមរវិទូ* និងអគារទី២ មានឈ្មោះថា *អគារតេជោទេវី*។ *អគារតេជោទេវី* ត្រូវសាងសង់នៅលើទីតាំងនៃអគារ A ។

ការជ្រើសរើសទីតាំងអគារ A ជាកន្លែងសាងសង់អគារតេជោទេវី ត្រូវឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បញ្ជាក់លើទិដ្ឋភាពសំខាន់ៗបី៖ ទី១ ទីតាំងដីនៅទីនេះនៅសល់ធំសមរម្យល្មមនឹងសាងសង់អគារថ្មីមួយនេះដែលអមដោយសួនច្បារព័ទ្ធជុំវិញ, ទី២ អគារA (អគារចាស់) មិនសាកសមសម្រាប់ការបណ្ដុះបណ្ដាលនិងការសិក្សាស្រាវជ្រាវជាន់ខ្ពស់នោះទេ ដោយគោលបំណងដំបូងក្នុងការសាងសង់អគារនេះ គឺមិនមែនសម្រាប់ជាកន្លែងស្រាវជ្រាវនិងបណ្ដុះបណ្ដាលនោះទេ តែជាកន្លែងសម្រាប់ចម្អិនអាហារ និងទទួលទានអាហារ ដែលនាំឱ្យអគារនេះមានលក្ខណៈស្មុគស្មាញ ពន្លឺមិនគ្រប់គ្រាន់ និងមានកន្លុកកន្លៀតច្រើន និងទី៣ កន្លែងនេះជាទីតាំងសំខាន់ ហើយល្អសម្រាប់ការទទួលភ្ញៀវ ដោយជាអគារនៅមុខគេក្នុងស្ថាប័ននេះ។

ដូចនេះ ទីតាំងនៃអគារ A ដែលមានកម្ពស់ត្រឹមតែមួយជាន់ត្រូវជំនួសដោយអគារដែលមានកម្ពស់បីជាន់ មានលក្ខណៈកាន់តែទំនើប ដោយបំពាក់នូវបរិក្ខារបច្ចេកវិទ្យាទំនើបឆ្លើយតបនឹងខ្លឹមសាររបស់អគារ សាកសមជាកន្លែងអប់រំបណ្ដុះបណ្ដាលកម្រិតស្ដង់ដាខ្ពស់សម្រាប់ជាតិ។ លក្ខណៈពិសេសមួយទៀតនៃអគារតេជោទេវីគឺនៅជាន់ទី៣ មានបន្ទប់ដែលអាចរៀបចំកម្មវិធីសន្និសីទ សិក្ខាសាលា តុមូល និងកម្មវិធី ផ្សេងៗ ដែលអាចដាក់អ្នកចូលរួមបានប្រមាណ ៤០០នាក់ ដែលកន្លងមក រាជបណ្ឌិត្យសភាកម្ពុជាមិនធ្លាប់មានទីកន្លែងសម្រាប់រៀបចំកម្មវិធីនានា ដែលអាចទទួលអ្នកចូលរួមបានលើសពី ២០០នាក់ឡើយ[៨]។

[៨] សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា (សម្ភាសថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩)។




ប្លង់អគាររាជបណ្ឌិត្យសភាកម្ពុជាក្នុងអាណត្តិឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច

## II. ការដាក់ឈ្មោះអគារ « ឥន្ទ្រទេវី » និងបដិមាព្រះនាងឥន្ទ្រទេវី

### ១- ការដាក់ឈ្មោះអគារ «ឥន្ទ្រទេវី»

«អគារឥន្ទ្រទេវី» ជាសមិទ្ធផលថ្មីមួយរបស់រាជបណ្ឌិត្យសភាកម្ពុជាក្នុងអាណត្តិដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ក្រោមការឧបត្ថម្ភពី**សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន** តាមរយៈអ្នកឧកញ៉ា ពុង ឃាវសែ និងសាងសង់ដោយក្រុមការងារអ្នកឧកញ៉ាផ្ទាល់។

គោលបំណងនៃការសាងសង់អគារនេះគឺ ដើម្បីបំពេញតម្រូវការនៃការរីកចម្រើនរបស់រាជបណ្ឌិត្យសភាកម្ពុជាលើបីចំណុចសំខាន់គឺ ចំណុចទី១ ជាកន្លែងបណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) និងថ្នាក់បណ្ឌិតភាសាចិន ចំណុចទី២ ជាមជ្ឈមណ្ឌលបកប្រែភាសាបរទេស (ជាទិសដៅនាពេលអនាគត រាជបណ្ឌិត្យសភាកម្ពុជាមានបំណងប្រមូលផ្ដុំអ្នកមានចំណេះដឹងខាងភាសាផ្សេងៗ ហើយសុំសិទ្ធិធ្វើការបកប្រែនូវរាល់ស្នាដៃឬផលិតផលដែលមានតម្លៃសម្រាប់ជាតិមកជាភាសាខ្មែរ) និងចំណុចទី៣ ជាកន្លែងស្រាវជ្រាវ ប្រមូលផ្ដុំបញ្ញវន្ត តាមរយៈការរៀបចំសិក្ខាសាលា សន្និសីទ និងកម្មវិធីតុមូលផ្សេងៗ សម្រាប់បញ្ញវន្តធ្វើការវិភាគអំពីបញ្ហាសង្គម នយោបាយ សេដ្ឋកិច្ច បច្ចេកវិទ្យាទំនើបៗរបស់ពិភពលោកថ្មីៗនេះផងដែរ។ ជារួម អគារនេះនឹងជាទីបម្រើដល់បញ្ញវន្តទាំងខាងផ្នែកវិទ្យាសាស្ត្រពិតនិងវិទ្យាសាស្ត្រសង្គម ដើម្បីឱ្យបញ្ញវន្តទាំងឡាយបានបង្ហាញស្នាដៃរបស់ខ្លួនសម្រាប់ការរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ[៩]។

ដើម្បីឱ្យស្របតាមគោលបំណងនៃខ្លឹមសាររបស់អគារ ដែលនឹងបម្រើដល់វិស័យអភិវឌ្ឍធនធានមនុស្សនិងជាកន្លែងប្រមូលផ្ដុំបញ្ញវន្តកម្រិតខ្ពស់សម្រាប់ជួយប្រទេសជាតិ ស្របទៅតាមបេសកកម្មចម្បងរបស់រាជបណ្ឌិត្យសភាកម្ពុជា ពោលគឺការសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាលនោះ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច បានផ្ដួចផ្ដើមគំនិតដោយដាក់ឈ្មោះអគារនេះថា «អគារឥន្ទ្រទេវី» ដែលតាមប្រវត្តិសាស្ត្រខ្មែរ ព្រះនាងឥន្ទ្រទេវីជាអគ្គមហេសីទី២ របស់ព្រះបាទជ័យវរ្ម័នទី៧ និងជាវីរនារីមួយរូបរបស់ជាតិនាសម័យអង្គរលើវិស័យអប់រំជាន់ខ្ពស់របស់ជាតិ[១០]។ ព្រះនាងឥន្ទ្រទេវីជាអ្នកដែលបានយកចិត្តទុកដាក់លើការងារ អប់រំនិងបណ្ដុះបណ្ដាល ខណៈដែលនៅសម័យនោះ ខ្មែរមានផ្នត់គំនិតផ្ដោតតែលើការងារក្នុងផ្ទះជាជាងការរៀនសូត្រ។ ដូច្នេះ ការដាក់ឈ្មោះអគារនេះថា «អគារឥន្ទ្រទេវី» គឺដើម្បីជាការនឹកដល់ផ្នែកវិទ្យាសាស្ត្រនិងការអប់រំបណ្ដុះបណ្ដាលនៅសម័យអង្គរ។

ទន្ទឹមនេះ ឯកឧត្តមបណ្ឌិតចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងសហការី បានសម្រេចសាងសង់បដិមាព្រះនាងឥន្ទ្រទេវីតម្កល់នៅបរិវេណក្បែរអគារនេះជានិមិត្តរូប ដើម្បីជាការរំលឹក

[៩] សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា (សម្ភាសថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩)

[១០] យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា (សម្ភាសថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩)

ឱ្យកូនខ្មែរជំនាន់ក្រោយបានចងចាំពីគុំរូវីរភាពនារីខ្មែរសម័យអង្គរ ដែលបានជួយដល់ប្រទេសជាតិយ៉ាងច្រើន ហើយក៏ដើម្បីនាំឱ្យមានការឯកភាពគ្នាលើអត្តសញ្ញាណព្រះនាងឥន្ទ្រទេវីដែរ។




ប្លង់អគារឥន្ទ្រទេវី (មើលពីមុខ បែរមុខទៅទិសខាងកើត)

## ២- ការកំណត់អត្តសញ្ញាណព្រះនាងឥន្ទ្រទេវី

ព្រះកិត្តិនាមព្រះនាងឥន្ទ្រទេវីត្រូវបានអ្នកសិក្សាស្រាវជ្រាវទាំងជាតិ និងអន្តរជាតិ បានដឹង បានឮស្ទើរគ្រប់ៗគ្នា ដោយសារមានតឹកតាងសិលាចារឹកបន្សល់ទុកពីស្នាដៃរបស់ព្រះនាង។ ព្រះនាងជាវីរនារីខ្មែរមួយរូបដែលមានស្នាដៃក្នុងវិស័យអប់រំ ទាំងភាសាសាស្ត្រ និងព្រះពុទ្ធសាសនា។ ក៏ប៉ុន្តែទោះបីព្រះនាងមានព្រះនាមល្បីល្បាញដែលត្រូវចាត់ទុកជាកំពូលវីរនារីរបស់ជាតិក្តី ក៏បដិមាព្រះនាងមិនទាន់មានការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់នៅឡើយទេ។

ដោយមានតម្រូវការកសាងបដិមាព្រះនាងឥន្ទ្រទេវីជានិមិត្តរូបតម្កល់នៅក្បែរអគារឥន្ទ្រទេវី ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា តាមរយៈឯកឧត្តមបណ្ឌិត យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំក្រុមការងារស្រាវជ្រាវមួយដឹកនាំដោយលោកបណ្ឌិត ផុន កសិកា អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា និងក្រុមការងារស្រាវជ្រាវមាន លោក ប្រែង ពិសិដ្ឋ លោក ហឿង សុជារស់ លោកស្រី ម៉ិល វាសនា និងកញ្ញា តាកេត ស័កដា ដើម្បីសិក្សាផ្ទៀងផ្ទាត់បដិមាព្រះនាងឥន្ទ្រទេវី នៅតាមប្រាសាទនានាក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ពិសេសនៅតំបន់អង្គរ ខេត្តសៀមរាប។

បន្ទាប់ពីក្រុមការងារបានសិក្សាស្រាវជ្រាវលើឯកសារផ្សេងៗ និងបានចុះសិក្សាអង្កេតរូបចម្លាក់នៅតាមប្រាសាទដែលកសាងឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ក្រុមស្រាវជ្រាវបានកំណត់សម្គាល់នូវអត្តសញ្ញាណរូបមួយចំនួននៅតាមប្រាសាទ ដែលបង្ហាញអត្តសញ្ញាណជាមហេសីរបស់ព្រះបាទជ័យវរ័ន្មទី៧។ រូបចម្លាក់ទាំងនោះត្រូវគេឆ្លាក់នៅសងខាងទ្វារ នៅតាមសសរ តាមជញ្ជាំងនៃថែវខាងក្នុង និងនៅជាន់ខាងលើនៃប្រាសាទ។ នៅតាមជញ្ជាំងនៃថែវខាងក្នុង ចម្លាក់បដិមាដែលទ្រង់គ្រឿងក្នុងទម្រង់ជាព្រះមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ ខ្លះបង្ហាញមានចំនួន២អង្គ និងខ្លះទៀតមានបង្ហាញចំនួនលើសពី២អង្គ។

លោកស្រី ង៉ិន ផល្លីកា ដែលជាអ្នកនិពន្ធសៀវភៅមានចំណងជើងថា « ត្រៃក្សត្រ » បានសិក្សានិងកំណត់ត្រៃក្សត្រ (ព្រះបាទជ័យវរ័ន្មទី៧ ព្រះនាងជ័យរាជទេវី និងព្រះនាងឥន្ទ្រទេវី) ដោយប្រើវិធីសិក្សាប្រៀបធៀបរូបចម្លាក់ទាំងឡាយនៅតាមប្រាសាទក្នុងរាជព្រះបាទជ័យវរ័ន្មទី៧ ហើយវិភាគពិចារណាកំណត់អត្តសញ្ញាណលើក្សត្រទាំងបីអង្គនោះ។ លោកស្រីបានកំណត់លក្ខណៈសម្គាល់នៃត្រៃក្សត្រដោយផ្តោតលើ ទម្រង់មកុដ សង្វារព័ន្ធ សម្លៀកបំពាក់ និងកាយវិការ។ លោកស្រីបានបញ្ជាក់ថាលក្ខណៈជាស្តេចគឺមានគ្រឿងសម្គាល់ខុសពីមនុស្សទូទៅ និងទេវតា។

តាមកំណត់ត្រារបស់ ជីវ តាក្វាន់ ដែលបានមកដល់ប្រទេសកម្ពុជានៅចុងសតវត្សរ៍ទី១៣ បានលើកឡើងថា ព្រះមហាក្សត្រមានមហេសីចំនួន៥អង្គ គឺព្រះអគ្គមហេសីមួយអង្គ និងមហេសីបួនអង្គប្រចាំទិស[១១]។ តាមរយៈសិលាចារឹកប្រាសាទភិមានអាកាស K. 485[១២] បានឱ្យដឹងថា ព្រះនាងឥន្ទ្រទេវី ជាអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ និងជាម្ចាស់បងរបស់ព្រះនាងជ័យរាជទេវី បានសាងរូបបដិមាព្រះនាងជ័យរាជទេវី ជាមួយព្រះបាទជ័យវរ្ម័នទី៧ និងព្រះនាងផ្ទាល់ នៅគ្រប់បណ្តាខេត្តដែលគ្រប់គ្រងដោយព្រះបាទជ័យវរ្ម័នទី៧[១៣]។

តាមការចុះសិក្សាស្រាវជ្រាវ និងអង្កេត ផ្ទៀងផ្ទាត់ផ្ទាល់លើរូបចម្លាក់តាមប្រាសាទនានាក្នុងរាជព្រះបាទជ័យវរ័ន្មទី៧ ក្រុមស្រាវជ្រាវបានសង្កេតឃើញថា រូបស្ត្រីទ្រង់គ្រឿងជាលក្ខណៈមហេសីគង់នៅជាប់ជិតនឹងព្រះបាទជ័យវរ្ម័នទី៧ ភាគច្រើនគឺមានចំនួន៣អង្គ ជាជាងមានចំនួន២អង្គ ៤អង្គ និង៥អង្គ។ ចំណុចនេះបានក្លាយជាចំណោទសួរមួយសម្រាប់ក្រុមស្រាវជ្រាវ ដែលទាមទារឱ្យមានការបកស្រាយតាមរយៈជំនួបរវាងអ្នកជំនាញដើម្បីកំណត់អត្តសញ្ញាណមហេសីទាំងនោះ ជាពិសេសការកំណត់អត្តសញ្ញាណព្រះនាងឥន្ទ្រទេវី។

នៅថ្ងៃព្រហស្បតិ៍ ១០រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំអង្គសិក្ខាសាលាតុមូលមួយ ដែលមានការចូលរួមពីវាគ្មិន

---

[១១] លី ធាមតេង កំណត់ហេតុរបស់ជីវតាក្វាន់អំពី *ប្រពៃណីនៃអ្នកស្រុកចេនឡា* ភ្នំពេញ ឆ្នាំ១៩៧៣ ទំព័រ២៥។

[១២] George Coedès *Inscription Du Cambodge,* Volume II, Hanoi, p. 161-181

[១៣] George Coedès *បដិមានៃព្រះរាជាខ្មែរជ័យវរ្ម័នទី៧* ក្នុង ឧទ័យ លេខ៣ ឆ្នាំ២០០២ ទំព័រ ៨៣។

ជំនាញជាតិនិងអន្តរជាតិ ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា សារមន្ទីរជាតិភ្នំពេញ និងស្ថាប័នស្រាវជ្រាវជាតិនិងអន្តរជាតិដទៃទៀត ដើម្បីសម្រេចកំណត់អត្តសញ្ញាណបដិមាព្រះនាងឥន្ទ្រទេវី សម្រាប់កសាងជាបដិមាទោលនៅក្បែរបរិវេណអគារឥន្ទ្រទេវី។ ជាលទ្ធផល អង្គសិក្ខាសាលាបានសម្រេចកំណត់យកអត្តសញ្ញាណព្រះនាងឥន្ទ្រទេវីជារូបចម្លាក់ដែលឆ្លាក់នៅប្រាសាទព្រះខ័ន ក្នុងតំបន់អង្គរ ខេត្តសៀមរាប។ អង្គសិក្ខាសាលាបានអនុម័តកំណត់ឆ្លាក់រូបទោល ដោយផ្ដិតយករូបភាព និងក្បាច់លម្អទាំងឡាយ មាន គ្រឿងអលង្ការ មកុដរាងក្រពុំឈូក មុក្តាហារ(ខ្សែក) ក្រវិល សង្វារព័ន្ធ (ធៀងខ្វែង) កម្រងផ្កា ផ្កាឈូក សំពត់ ខ្សែក្រវ៉ាត់សំពត់ ជើងទម្រផ្កាឈូកដែលមានសត្វក្រពើព័ទ្ធ និងគ្រឿងលម្អផ្សេងៗទៀត ឱ្យដូចរូបចម្លាក់ដែលបានកំណត់នោះ។

### ៣- បដិមាព្រះនាងឥន្ទ្រទេវី និងសំណង់បុស្បុកតម្កល់បដិមាព្រះនាង

#### បដិមាព្រះនាងឥន្ទ្រទេវី

បន្ទាប់ពីក្រុមអ្នកស្រាវជ្រាវ និងក្រុមអ្នកជំនាញបានកំណត់សម្រេចលើអត្តសញ្ញាណបដិមាព្រះនាងឥន្ទ្រទេវីរួចមក រាជបណ្ឌិត្យសភាកម្ពុជាត្រូវរៀបចំសិតបដិមាព្រះនាងឥន្ទ្រទេវីជារូបទោលលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រ។ បដិមាព្រះនាងគឺសិតអំពីស្ពាន់ មានកម្ពស់១,៥៧ម៉ែត្រ (គិតពីព្រះបាតដល់ព្រះសិរ) និងមានទំហំដងខ្លួនសមាមាត្រទៅនឹងរូបចម្លាក់ពិតដែលឆ្លាក់នៅប្រាសាទព្រះខ័ន។ ដំណើរការសិតបដិមាព្រះនាងឥន្ទ្រទេវីមានច្រើនដំណាក់កាលគឺ ដំណាក់កាលសូនឬប៉ាន់រូបពីដីឥដ្ឋ ដំណាក់កាលធ្វើពុម្ពចម្លង ដំណាក់កាលធ្វើបដិមាក្រមួននិងធ្វើពុម្ពដុត ដំណាក់កាលដុតពុម្ព ដំណាក់កាលសិតបដិមា និង ដំណាក់កាលផ្ដុំសម្រេច។

ការសិតបដិមាព្រះនាងឥន្ទ្រទេវីបានប្រព្រឹត្តទៅយ៉ាងឱឡារិកនៅវេលាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ នៅរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ព្រមទាំងសម្ដេចព្រះសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដំណើរការសិតបដិមានេះបានប្រើស្ពាន់អស់ប្រមាណ ២០០គីឡូក្រាម និងបានចំណាយអស់រយៈពេលប្រមាណ៣ម៉ោង[១៥]។ លោកជំទាវឧកញ៉ា សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ជាអ្នកឧបត្ថម្ភការសិតបដិមានេះដោយត្រូវចំណាយថវិកាអស់ចំនួន ១២៦,០០$ (ដប់ពីរពាន់ប្រាំមួយរយដុល្លារអាម៉េរិក)។ ជាងនេះទៅទៀត លោកជំទាវឧកញ៉ា ក៏បានទទួលរ៉ាប់រងការចំណាយលើការរៀបចំកម្មវិធីសិតបដិមាដ៏អធិកអធមនេះផងដែរ។

[១៥] ព្រាប សោភ័ណ អ្នកជំនាញខាងសំណង់បុរាណ (សម្ភាសថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩)។




ព្រះវត្តមានសម្តេចព្រះសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ចូលរួមជាអធិបតីក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច និងលោកជំទាវឧកញ៉ា សៀង ចាន់ហេង
ដាក់កាក់ស្ពាន់ចូលក្នុងបាវសេម្រាប់ស្ល




សកម្មភាពស្លកាក់ស្ពាន់



សកម្មភាពសិតស្ពាន់ចូលពុម្ព ពីកំពូលមកុដដល់ចង្កេះ ពុម្ពពីចង្កេះសំពត់ដល់ជាយសំពត់ខាងក្រោម
និងពុម្ពប្រអប់ជើង និងជើងទម្រ

បដិមាព្រះនាងឥន្ទ្រទេវីសាងពីស្ពាន់បន្ទាប់ពីសិតរួចរាល់



បដិមាព្រះនាងឥន្ទ្រទេវីសាងពីស្ពាន់បន្ទាប់ពីសិតរួចរាល់



បដិមាព្រះនាងឥន្ទ្រទេវីលាបពណ៌ទង់ដែងក្រម៉ៅ
(រូបថតក្នុងពិធីព្រះរាជាភិសេកនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩)

## សំណង់បុស្បុកតម្កល់បដិមាព្រះនាងឥន្ទ្រទេវី

- ប្លង់សំណង់បុស្បុក




ប្លង់បុស្បុកតម្កល់បដិមាព្រះនាងឥន្ទ្រទេវី

បដិមាព្រះនាងឥន្ទ្រទេវីត្រូវតម្កល់រក្សាជាទីគោរពសក្ការៈក្នុងបុស្បុក (ប្រាសាទ) ដែលសាងសង់នៅក្បែរដើមត្នោតបីដើម (ត្នោតឈ្មោលមួយដើមនិងត្នោតញីចំនួនពីរដើម) នៅទិសឰសាននៃអគារឥន្ទ្រទេវី។ សំណង់បុស្បុកនេះសាងសង់ពីបេតុងនិងថ្មភក់ មានបាតទំហំ៩ម៉ែត្រក្រឡា និងមានកម្ពស់៩ម៉ែត្រ។ សំណង់បុស្បុកនេះទទួលបានជំនួយសាងសង់ពីលោកជំទាវឧកញ៉ា សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ក្នុងទឹកប្រាក់ចំនួន ២២០,០០$ (ម្ភៃពីរពាន់ដុល្លារអាម៉េរិក) ព្រមទាំងសួនច្បារសម្រាប់លម្អជុំវិញបុស្បុកជាទឹកប្រាក់ចំនួន ២,០០០$ (ពីរពាន់ដុល្លារអាម៉េរិក)ទៀត។

នៅព្រឹកថ្ងៃអាទិត្យទី១ ខែកញ្ញា ឆ្នាំ២០១៩ ឯកឧត្តមបណ្ឌិត យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា និងមន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំសែនព្រេនក្រុងពាលីសុំម្ចាស់ទឹកម្ចាស់ដីបើកការដ្ឋានសាងសង់សំណង់បុស្បុកសម្រាប់តម្កល់រក្សាបដិមាព្រះនាងឥន្ទ្រទេវី តាមទំនៀមប្រពៃណី។



ពិធីសែនព្រេនបើកការដ្ឋានសាងសង់បុស្បុក



ការរៀបចំគ្រឹះបុស្បុក



សំណង់បុស្បុកបន្ទាប់ពីសង់រួច (មើលពីទិសខាងជើង)



សំណង់បុស្បុកបន្ទាប់ពីសង់រួច (មើលពីទិសខាងលិច)

## III. ការរៀបចំប្លង់ស្ថាបត្យកម្ម និងដំណើរការសាងសង់

១- ការរៀបចំប្លង់ស្ថាបត្យកម្ម

អគារឥន្ទ្រទេវីមានកម្ពស់បីជាន់ ស្មើនឹង១៨ម៉ែត្រ មានបណ្តោយប្រវែង៤០ម៉ែត្រ ទទឹង១៧ម៉ែត្រ សាងសង់លើខឿនខ្ពស់ផុតពីដី បំពាក់ដោយល្បាក់ មានជណ្តើរប្រាំកាំ(កម្ពស់៩តឹកកន្លះ) និងសាងសង់បែរមុខទៅទិសខាងកើត[១៥]។ ការសាងសង់អគារនេះបានធ្វើឡើងដោយមានការសិក្សាត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយមានការរៀបចំរចនាតាមបែបស្ថាបត្យកម្ម មានវិស្វករសិក្សាគ្រឿងបង្កុំសំណង់ មានការសិក្សាស្រទាប់ដី គ្រឹះ ធ្នឹម រហូតដល់ការប្រើប្រាស់ដែក ជាដើម។ អគារនេះមានពណ៌ពងមាន់ខ្ចី។

សំណង់អគារឥន្ទ្រទេវីកសាងឡើងអំពីបេតុង និងឥដ្ឋ ដំបូលគ្រោងដែក ប្រក់ក្បឿងស្រកាលិញ។ វាជាប្រភេទអគារខ្មែរទំនើប ដែលមានដំបូលប៉ិត ជារចនាបថបែបខ្មែរបំពាក់ដោយអំពូលម៉ែត្រ និងចុងចែង (កន្ទុយទា)។ នៅលើក្លោងទ្វារ មានចារឹកឈ្មោះ *អគារឥន្ទ្រទេវី* ហើយហោជាងលម្អដោយក្បាច់ភ្ញីទេស។ ចំណែកឯដៃស្នាទ្រដំបូលអគារនេះគឺធ្វើអំពីដែកទីបជ្រុងពត់ចេញជារាងកោង។

បង្អួចអគារបំពាក់ដោយអាលុយមីញ៉ូមនិងកញ្ចក់ ដែលមានទំហំធំ ខ្ពស់ វែង ស្រឡះល្អដើម្បីជួយឱ្យមានពន្លឺជះចូលបានគ្រប់គ្រាន់។ ទិដ្ឋភាពខាងក្នុងជាន់នីមួយៗនៃអគារ មានពណ៌ស និងមានក្រាលការ៉ូពណ៌សលាយសារាយដើម្បីជួយឱ្យមានពន្លឺភ្លឺផង និងជួយឱ្យចំណាយភ្លើងតិចផង។ ម្យ៉ាងអគារនេះផ្តោតលើការសិក្សាបណ្តុះបណ្តាលជាសំខាន់ ហេតុនេះការរចនាក៏ត្រូវទាក់ទងនឹងការជួយឱ្យស្ងប់អារម្មណ៍ផងដែរ ដោយកុំឱ្យបរិស្ថានរបស់វាឆើតឆាយពេកនិងកុំស្រអាប់ពេក។ អគារនេះមានបំពាក់ជណ្តើរយន្តមួយដែលផ្ទុកមនុស្សបាន១៨នាក់ និងមានជណ្តើរជើងក្រាលដោយម៉ាបប្រវែងប្រមាណ១,៨ម៉ែត្រ និងមានបង្កាន់ដៃធ្វើអំពីឈើ និងដែក។

នៅខាងមុខផ្នែកខាងស្តាំនៃច្រកចូលអគារ មានបញ្ចុះស្លាកបឋមសិលាដែលខ្លឹមសារថា «**អគារឥន្ទ្រទេវី** អំណោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តាមរយៈអ្នកឧកញ៉ា ពុង ឃាវសែ លោកជំទាវ លឹម សុផានី»។ ចំណែកនៅផ្នែកខាងឆ្វេងនៃអគារមានផ្លូវជម្រាល (មិនមានកាំជណ្តើរ) សម្រាប់ជនពិការ។ ថវិកាដែលចំណាយលើសំណង់អគារឥន្ទ្រទេវីទាំងមូល សម្ភារៈបរិក្ខារ និងប្រព័ន្ធ អេឡិចត្រូនិក និងការរៀបចំទីធ្លា សួនជុំវិញអគារ (លើកលែងសួនជុំវិញបុស្បុកតម្កល់ព្រះនាងឥន្ទ្រទេវីដែលជាថវិកាជំនួយបន្ថែមពីលោកជំទាវ សៀង ចាន់ហេង ចំនួន២,០០០$) សរុបជាទឹកប្រាក់ចំនួន ១, ៥៤៦, ៩៤៤, ៣០$ (មួយលានប្រាំរយសែសិបប្រាំមួយពាន់ប្រាំបួនរយសែសិបបួន និងសាមសិបសេន ដុល្លារសហរដ្ឋអាម៉េរិក)។

---

[១៥] ចំរើន ដេន និង ឯម សុភក្តិ ក្រុមសំណង់ស្ថាបត្យកម្មសាងសង់អគារឥន្ទ្រទេវី (សម្ភាសថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩)។



N
BM04
កន្លែងបោះប៊ូល
ផ្លូវចាស់
ផ្លូវបេតុង
25/01/2019


4.00
40.00
3.00
7.00
20.00
i=30
25/01/2019



25/01/2019
40.00
4.00
23.23
0.95
4.50
6.23
0.80
±0.00
+4.50m
+8.50m
+12.50m
+17.00m
+23.23m
-0.95m




## រូបភាពមើលពីក្រោយ

មាត្រដ្ឋាន ១:១៥០

| ល.រ | ថ្ងៃ ខែ ឆ្នាំ | កំណែ | មុខងារ | ឈ្មោះ - មុខងារ | ហត្ថលេខា | ថ្ងៃ ខែ ឆ្នាំ | បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: | | | ម្ចាស់សំណង់ : |
|---|---|---|---|---|---|---|---|---|---|---|
| | | | គូរដោយ : | លោក ចំរើន ជេន (ស្ថាបត្យករ) | | 25/01/2019 | | | | |
| | | | គណនាដោយ : | | | | ទីតាំងសាងសង់ : | | | - |
| | | | សិក្សាដោយ : | លោក ចំរើន ជេន (ស្ថាបត្យករ) | | | | | | |
| | | | ពិនិត្យដោយ : | លោក មាស ជាំងមុនី (ប្រធានគម្រោង) | | | ឈ្មោះគំរោង : អគារ ៩ជាន់ | មាត្រដ្ឋាន | ចំនួនសន្លឹក | លេខសន្លឹក |
| | | | យល់ព្រមដោយ : | លោក លីម សុវុត្ថាត (ពីណាយក្រុមប្រឹក្សាភិបាល រាជបណ្ឌិត្យសភាកម្ពុជា) | | | ឈ្មោះប្លង់ : រូបភាពមើលពីក្រោយ | ១:១៥០ | ១១ | ០៧ |




**រូបភាពមើលពីស្តាំ**

មាត្រដ្ឋាន ១:១៥០

| ល.រ | ថ្ងៃ ខែ ឆ្នាំ | កំណែ | មុខងារ | ឈ្មោះ - មុខងារ | ហត្ថលេខា | ថ្ងៃ ខែ ឆ្នាំ |
|---|---|---|---|---|---|---|
| | | | គូរដោយ : | លោក ចំរើន ជេន (ស្ថាបត្យករ) | | 25/01/2019 |
| | | | គណនាដោយ : | | | |
| | | | សិក្សាដោយ : | លោក ចំរើន ជេន (ស្ថាបត្យករ) | | |
| | | | ពិនិត្យដោយ : | លោក មាស ជាំរ៉ាមុនី (ប្រធានគម្រោង) | | |
| | | | យល់ព្រមដោយ : | លោក លឹម សុក្រាត (តំណាងអ្នកបច្ចេកទេស រាជបណ្ឌិត្យសភាកម្ពុជា) | | |

| | | | |
|---|---|---|---|
| បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: | ម្ចាស់សំណង់ : | | |
| ទីតាំងសាងសង់ : | - | | |
| ឈ្មោះគំរោង : អគារ ៩ធ្នូនទី | មាត្រដ្ឋាន | ចំនួនសន្លឹក | លេខសន្លឹក |
| ឈ្មោះប្លង់ : រូបភាពមើលពីស្តាំ | ១:១៥០ | ១១ | ០៨ |


7.00
3.00
7.00
3.00
17.00
0.95
4.50
4.00
4.00
4.50
5.58
22.58
±0.00
+4.50m
+8.50m
+12.50m
+17.00m
+22.56m
-0.95m
25/01/2019


4.00
40.00
4.50
6.17
23.17
0.95
+0.00
+4.50m
+8.50m
+12.50m
+17.00m
+19.50m
-0.95m
25/01/2019




**រូបភាពពុះ ខ_ខ**

មាត្រដ្ឋាន ១:១៥០

| ល.រ | ថ្ងៃ ខែ ឆ្នាំ | កំណែ | មុខងារ | ឈ្មោះ - មុខងារ | ហត្ថលេខា | ថ្ងៃ ខែ ឆ្នាំ | បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: | ម្ចាស់សំណង់ : | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | គូរដោយ : | លោក ចំរើន ដេន (ស្ថាបត្យករ) | | 25/01/2019 | | | | |
| | | | គណនាដោយ : | | | | ទីតាំងសាងសង់ : | | | |
| | | | សិក្សាដោយ : | លោក ចំរើន ដេន (ស្ថាបត្យករ) | | | | - | | |
| | | | ពិនិត្យដោយ : | លោក មាស ដារ៉ាមុនី (ប្រធានគម្រោង) | | | ឈ្មោះគំរោង : **អគារ [illegible]** | មាត្រដ្ឋាន | ចំនួនសន្លឹក | លេខសន្លឹក |
| | | | យល់ព្រមដោយ : | លោក លឹម សុក្រាត (តំណាងអ្នកបច្ចេកទេស វាស់វេស្ថាបត្យករកម្ពុជា) | | | ឈ្មោះប្លង់ : រូបភាពពុះ ខ-ខ | ១:១៥០ | ១១ | ១១ |

## ២- ដំណើរការសាងសង់

ការសាងសង់អគារតេជោទេវីគឺត្រូវជ្រើសរើសការសាងសង់នៅទីតាំងអគារA នៃរាជបណ្ឌិត្យសភាកម្ពុជា ដោយអគារAនេះទៀតសោធ សាងសង់ឡើងដំបូងក្នុងគោលបំណងជាទីកន្លែងទទួលទានអាហារដែលពុំមានសក្តានុពលក្នុងការបម្រើជាប្រយោជន៍ទៅតាមការវិវឌ្ឍថ្មីរបស់ស្ថាប័ន ជាពិសេសការងារបណ្តុះបណ្តាល។ ជាងនេះទៅទៀត នៅក្នុងបរិវេណនៃរាជបណ្ឌិត្យសភាកម្ពុជាគឺពុំមានទីលំហទំនេរ ឬទីកន្លែងសក្តិសមណាជាងទីតាំងនេះឡើយ។ ដូច្នេះហើយទើបថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជាសម្រេចជ្រើសយកទីតាំងនេះ ដោយវាយអគារចាស់កម្ពស់មួយជាន់ចោល ហើយសាងសង់អគារតេជោទេវីដែលមានកម្ពស់បីជាន់នេះឡើង។

នៅរសៀលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងមន្ត្រីរាជការនៃរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំពិធីសែនក្រុងពាលី និងបុកគ្រឹះសាងសង់អគារតេជោទេវី នៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា។ បន្ទាប់ពីបើកការដ្ឋានសាងសង់ជាផ្លូវការរួចមក ដំណើរការសាងសង់អគារតេជោទេវីបានវិវឌ្ឍទៅក្នុងល្បឿនយ៉ាងលឿនគួរឱ្យកត់សម្គាល់។ ការសាងសង់អគារតេជោទេវីបានចំណាយរយៈពេលអស់១៤ខែ ដើម្បីបានរួចរាល់ជាស្ថាពរ ហើយបានសម្ពោធនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។



សកម្មភាពវាយផ្តួលអគារចាស់ដើម្បីយកទីតាំងសាងសង់អគារតេជោទេវី




ពិធីសែនក្រុងពាលីបុកគ្រឹះអគារឥន្ទ្រទេវី



វិឌ្ឍភាពនៃដំណើរការសាងសង់អគារឥន្ទ្រទេវី

### ការកែប្រែប្លង់អគារ

ដោយពិនិត្យឃើញថា ប្លង់ដំបូលអគារឥន្ទ្រទេវីមានលក្ខណៈប៉ិតជាច់ពេក ពុំសូវសមទំនងតាមលក្ខណៈខ្មែរ ថ្នាក់ដឹកនាំនិងអ្នកជំនាញនៃរាជបណ្ឌិត្យសភាកម្ពុជាបានស្នើសុំឱ្យមានការកែសម្រួលប្លង់ដំបូលអគារនេះឡើងវិញលើចំណុចធំៗបីគឺ ដំបូលខាងលើ ដំបូលបញ្ចោត និងដំបូលក្លោងទ្វារ។ ការកែសម្រួលប្លង់ដំបូលអគារនេះ ត្រូវដំណើរការទៅដោយកិច្ចប្រជុំជាបន្តបន្ទាប់រវាងថ្នាក់ដឹកនាំ និងអ្នក

ជំនាញនៃរាជបណ្ឌិត្យសភាកម្ពុជាជាមួយនឹងក្រុមស្ថាបត្យករគូរប្លង់អគារឥន្ទ្រទេវី។ ក្រោយមកទៀត រាជបណ្ឌិត្យសភាកម្ពុជាបានស្នើសុំឱ្យអ្នកឧកញ៉ា ពុង ឃាវសែ ជួយបំពាក់គ្រឿងបរិក្ខារក្នុងបន្ទប់មាន ដូចជា តុ កៅអី ម៉ាស៊ីនត្រជាក់ កង្ហារ LCD វាំងនន អំពូលភ្លើង កុំព្យូទ័រ បណ្ដាញអ៊ីនធឺណិត សម្រាប់បម្រើដល់ការសិក្សា ក៏ដូចជាកិច្ចការផ្សេងៗទៀតនៅក្នុងអគារនេះ។



កិច្ចប្រជុំកែប្រែប្លង់ដំបូលអគារ



អគារឥន្ទ្រទេវីផ្នែកខាងមុខ (ខាងកើត) និងចំហៀងខាងត្បូង (មើលពីទិសអាគ្នេយ៍)



អគារវេន្រ្ទទេវីផ្នែកចំហៀងខាងត្បូង ឆៀងខាងកើត (មើលពីទិសអាគ្នេយ៍)



អគារវេន្រ្ទទេវីផ្នែកខាងក្រោយ (ខាងលិច) និងចំហៀងខាងត្បូង (មើលពីទិសនិរតី)



អគារឥន្ទ្រទេវីផ្នែកខាងក្រោយ (ខាងលិច) (មើលពីអគារខេមរវិទូ)



អគារឥន្ទ្រទេវីផ្នែកចំហៀងខាងលិច ឆៀងខាងជើង



អគារឥន្ទ្រទេវីផ្នែកចំហៀងខាងកើត ឆៀងខាងជើង មានបុស្បុកតម្កល់បដិមាព្រះនាងឥន្ទ្រទេវី



អគារឥន្ទ្រទេវីផ្នែកខាងមុខ បែរមុខទៅទិសខាងកើត

**ដំណាក់កាលបញ្ចប់**

នៅដំណាក់កាលបញ្ចប់នៃដំណើរការសាងសង់អគារឥន្ទ្រទេវី មានការរៀបចំសម្អាតទីធ្លា រៀបចំសួន ដាំដើមឈើផ្កាលម្អនៅជុំវិញអគារ មាន ដើមលៀប ដើមច័ន អង្គារបុស្ស ដើមក្ទម្ព ដើមលឿងរាជ ដើមក្រោក ដើមអូញម៉ូញ ដើមពុល ដើមឥន្ទនេល ដើមរំដួល ដើមរាំងភ្នំ ដើមជើងគោ ដើមរាំងទឹក ដើមផ្កា ណាគ្រី និងដើមចំប៉ី។ ដើមឈើផ្កាទាំងនេះត្រូវបានជ្រើសរើសដាំដោយអង្គភាពចំណុះនានា របស់រាជបណ្ឌិត្យសភាកម្ពុជា។




ប្លង់សួនជុំវិញអគារឥន្ទ្រទេវី



សកម្មភាពដាំដើមឈើផ្កានៅផ្នែកក្រោយអគារឥន្ទ្រទេវី



សួននៅពីមុខអគារឥន្ទ្រទេវី



ទិដ្ឋភាពសួននៅផ្នែកខាងត្បូង និងខាងកើតនៃអគារឥន្ទ្រទេវី



ទិដ្ឋភាពសួននៅផ្នែកខាងកើត និងខាងត្បូងអគារឥន្ទ្រទេវី (រូបថតពីលើអគារC)



ទិដ្ឋភាពសួននៅផ្នែកខាងលិច និងខាងត្បូងអគារឥន្ទ្រទេវី (រូបថតពីលើអគារC)



សួននៅខាងមុខអគារជាប់នឹងអគារជ្រុងខាងជើង



សួននៅខាងមុខអគារជាប់នឹងអគារជ្រុងខាងត្បូង

## ៣- ការប្រើប្រាស់អគារ

### - ជាន់ផ្ទាល់ដី

នៅជាន់ផ្ទាល់ដីមានបន្ទប់ចំនួនប្រាំពីរ ដែលក្នុងនោះប្រើជាបន្ទប់សិក្សាចំនួនប្រាំមួយ និងបន្ទប់ការិយាល័យមួយ។ បន្ទប់នីមួយៗមានទំហំ ៧ម៉ែត្រ × ៨ម៉ែត្រ អាចផ្ទុកសិស្សបានចំនួន៣០នាក់។ ក្រៅពីនេះ មានឃ្លាំងមួយសម្រាប់ដាក់សម្ភារៈសម្អាត មានបន្ទប់បញ្ជាភ្លើងមួយ និងមានបន្ទប់ទឹកប្រុសរួមមួយនិងបន្ទប់ទឹកស្រីរួមមួយ។ នៅជាន់នេះមានលំហនៅពីមុខដែលរៀបចំដាក់កន្លែងសម្រាប់ភ្ញៀវអង្គុយរង់ចាំមួយ និងរៀបចំដាក់កន្លែងសម្រាប់និស្សិតចុះឈ្មោះសិក្សានិងសាកសួរព័ត៌មានផ្សេងៗមួយ[១៦]។


គំនូរប្លង់នៃការរៀបចំកន្លែងសម្រាប់ទទួលភ្ញៀវ

[១៦] សាន សុរាវនិត អនុប្រធានផ្នែកបណ្ដុះបណ្ដាល (សម្ភាសថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩)។



**- ជាន់ទី១**

នៅជាន់ទី១ មានបន្ទប់ចំនួនប្រាំបី ដែលក្នុងនោះប្រើជាបន្ទប់សិក្សាចំនួនប្រាំពីរ និងបន្ទប់ប្រជុំមួយ។ បន្ទប់សិក្សានីមួយៗមានទំហំ ៧ម៉ែត្រ × ៨ម៉ែត្រ អាចផ្ទុកសិស្សបានចំនួន៣០នាក់។ បន្ទប់សិក្សាមួយដែលស្ថិតនៅចំកណ្ដាលផ្លូវច្រកចូល មានមុខងារពីរ ពោលគឺជាបន្ទប់សម្រាប់និស្សិតការពារនិក្ខេបបទផងនិងជាបន្ទប់សម្រាប់សិក្សាផង។ ដោយឡែក បន្ទប់ប្រជុំមានទំហំ ៧ម៉ែត្រ × ១១,៥ម៉ែត្រ។

បន្ទប់ប្រជុំនេះមានលក្ខណៈតូចល្មមសម្រាប់កិច្ចប្រជុំបុគ្គលិក និស្សិត និងសាស្ត្រាចារ្យ។ ក្រៅពីនេះ មានបន្ទប់ទឹកប្រុសរួមមួយនិងបន្ទប់ទឹកស្រីរួមមួយ។



**- ជាន់ទី២**

នៅជាន់ទី២ មានបន្ទប់ចំនួនប្រាំបី ដែលក្នុងនោះប្រើជាបន្ទប់សិក្សាធម្មតាចំនួនប្រាំមួយ និង ប្រើជាបន្ទប់ Lab ចំនួនពីរ (Lab សម្រាប់ភាសា និង Lab សម្រាប់កុំព្យូទ័រ)។ បន្ទប់ Lab នីមួយៗមាន បំពាក់កុំព្យូទ័រចំនួន៣០គ្រឿង។ បន្ទប់សិក្សាជាន់ទី២ មានទំហំប៉ុនគ្នានឹងបន្ទប់សិក្សានៅជាន់ទី១ និង មានបន្ទប់ទឹកប្រុសរួមមួយនិងបន្ទប់ទឹកស្រីរួមមួយ។



**- ជាន់ទី៣**

នៅជាន់ទី៣ មានសាលសន្និសីទ(សាលសហសិក្សា)មួយ ដែលមានទំហំ ១៧ម៉ែត្រ × ២៩ម៉ែត្រ អាចផ្ទុកអ្នកចូលរួមបានចំនួនជាង៤០០នាក់។ លក្ខណៈពិសេសនៅក្នុងសាលសហសិក្សា (សាលសន្និសីទ) នេះគឺមានការរៀបចំជាឆាកមួយនិងមានបំពាក់ LCD ខ្នាតធំចំនួនពីរ។ នៅជាន់នេះក៏មានលំហសម្រាប់ជួបជុំគ្នាសម្រាកហូបអាហារសម្រន់ផ្សេងៗនៅពេលមានកម្មវិធីសិក្ខាសាលា តុមូល ឬសន្និសីទ ផងដែរ។




ជារួម អគារឥន្ទ្រទេវីមានបន្ទប់ចំនួន២៤ ដែលក្នុងនោះប្រើជាបន្ទប់ការិយាល័យ១ បន្ទប់ប្រជុំខ្នាតតូចចំនួន១ បន្ទប់ការពារនិក្ខេបបទចំនួន១ បន្ទប់សិក្សាចំនួន១៨ បន្ទប់Labចំនួន២ និងសាលសន្និសីទ(សាលសហសិក្សា)ចំនួន១។ បន្ទប់នីមួយៗមានបំពាក់គ្រឿងបរិក្ខារសម្រាប់សិក្សា មានដូចជា តុសិស្ស តុគ្រូ LCD កង្ហារ ម៉ាស៊ីនត្រជាក់ និងអំពូលម៉ែត្រជាដើម[១៧]។ ក្រៅពីនេះ នៅជាន់នីមួយៗមានបន្ទប់ទឹកប្រុសរួមមួយនិងបន្ទប់ស្រីរួមមួយ។

[១៧] សាន សុភាវនិត អនុប្រធានផ្នែកបណ្ដុះបណ្ដាល(សម្ភាសថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩)។



ទិដ្ឋភាពបន្ទប់សិក្សាក្នុងអគារតេន្ទ្រទេវី



ទិដ្ឋភាពបន្ទប់កំព្យូទ័រក្នុងអគារតេន្ទ្រទេវី

អគារឥន្ទ្រទេវីជាសមិទ្ធផលថ្មីមួយក្នុងអាណត្តិដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច។ អគារនេះជាអំណោយរបស់**សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន** តាមរយៈអ្នកឧកញ៉ា ពុង ឃាវសែ ដើម្បីប្រើជាប្រយោជន៍ទៅតាមការវិវឌ្ឍថ្មីៗរបស់រាជបណ្ឌិត្យសភាកម្ពុជាជាពិសេសការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតលើជំនាញភាសាចិន និងជំនាញដទៃផ្សេងទៀត។ អគារឥន្ទ្រទេវីត្រូវបានសាងសង់ឡើងទៅតាមបទដ្ឋានបច្ចេកទេសយ៉ាងត្រឹមត្រូវ និងមានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដោយការគូរប្លង់ពីស្ថាបត្យករខ្មែរ សិក្សាគ្រឿងបង្គុំសំណង់ដោយវិស្វករខ្មែរសាងសង់ដោយក្រុមហ៊ុនខ្មែរ និងត្រួតពិនិត្យដោយថ្នាក់ដឹកនាំ និងអ្នកជំនាញនៃរាជបណ្ឌិត្យសភាកម្ពុជា។

ដោយផ្សារភ្ជាប់ទៅនឹងសមិទ្ធផលថ្មីនេះ បាននាំឱ្យលេចឡើងនូវសមិទ្ធផលថ្មីមួយទៀតក្នុងប្រវត្តិសាស្ត្រ នោះគឺការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវីជាលើកដំបូងបំផុតក្នុងប្រវត្តិសាស្ត្រ។ ក្នុងគោលបំណងកសាងបដិមាព្រះនាងឥន្ទ្រទេវីតម្កល់រក្សាជាទីគោរពសក្ការៈ ដើម្បីផ្សារភ្ជាប់នឹងនាមអគារឥន្ទ្រទេវី រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំក្រុមស្រាវជ្រាវ និងសិក្សាផ្ទៀងផ្ទាត់រូបចម្លាក់ព្រះនាងឥន្ទ្រទេវី ហើយបានរៀបចំសិក្ខាសាលាតុមូលបន្ថែមទៀតដើម្បីប្រមូលផ្តុំអ្នកស្រាវជ្រាវ និងអ្នកជំនាញជាតិ និងអន្តរជាតិពីស្ថាប័នផ្សេងៗ មកធ្វើបទបង្ហាញ និងជជែកពិភាក្សារហូតឈានទៅដល់ការឯកភាពគ្នាលើអត្តសញ្ញាណព្រះនាងឥន្ទ្រទេវី សម្រាប់ការកសាងបដិមាទោលរបស់ព្រះនាងនៅទីនេះ។ បដិមាទោលព្រះនាងឥន្ទ្រទេវីនៅរាជបណ្ឌិត្យសភាកម្ពុជា គឺជាគំរូដំបូងបង្អស់សម្រាប់ការកសាងបដិមាទោលរបស់ព្រះនាងនៅទីកន្លែងដទៃនាពេលក្រោយៗទៀត។ ការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវី និងបុស្បុកសម្រាប់តម្កល់បដិមាព្រះនាងនៅរាជបណ្ឌិត្យសភាកម្ពុជាទទួលបានជំនួយឧបត្ថម្ភពីលោកជំទាវឧកញ៉ា សៀង ចាន់ហេង។

## ឯកសារពិគ្រោះ

- ងិន ផល្លីកា *ត្រៃក្សត្រ* ភ្នំពេញ ឆ្នាំ២០១២
- លី ធាមតេង *កំណត់ហេតុរបស់ជីវតាក្វាន់អំពីប្រពៃណីនៃអ្នកស្រុកចេនឡា* ភ្នំពេញ ឆ្នាំ១៩៧៣
- George Coedès *បដិមានៃព្រះរាជាខ្មែរជ័យវរ្ម័នទី៧* ក្នុង ឧទ័យ លេខ៣ ឆ្នាំ២០០២ ទំព័រ៨៣-៨៨
- George Coedès *Inscription Du Cambodge,* Volume II, Hanoi, p. 161-181

## អ្នកផ្តល់បទសម្ភាស

- ចំរើន ដេន និង ឯម សុកក្តិ ក្រុមសំណង់ស្ថាបត្យកម្មសាងសង់អគារឥន្ទ្រទេវី (សម្ភាសថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៩)
- ព្រាប សោភ័ណ អ្នកជំនាញខាងសំណង់បុរាណ (សម្ភាសថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩)
- សាន សុវរនិត អនុប្រធានផ្នែកបណ្តុះបណ្តាល (សម្ភាសថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩)
- សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា (សម្ភាសថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩)
- សុខ ពិសិដ្ឋ ជាងស្មិត (សម្ភាសថ្ងៃទី៧ កញ្ញា ឆ្នាំ២០១៩)
- អ៊ុំ ប៉ុម ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា។